គណៈឆ្មបកម្ពុជា



ស្តង់ជា

ស្តីពី

ការចុះបញ្ជីឧទ្ទិសវិញ្ញ និងលក្ខខណ្ឌតម្រូវ

ក្នុងការអភិវឌ្ឍន៍វិជ្ជាជីវៈបន្តសម្រាប់ឆ្មបក្នុងព្រះរាជាណាចក្រកម្ពុជា

ខែតុលា ឆ្នាំ២០១៣

គណៈឆ្មបកម្ពុជា

ស្តង់ដានៃការចុះបញ្ជីឡើងវិញ និងលក្ខខណ្ឌតម្រូវក្នុងការអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត

សម្រាប់ឆ្មបក្នុងព្រះរាជាណាចក្រកម្ពុជា

១.សេចក្តីផ្តើម

ឆ្មបជនជាតិខ្មែរត្រូវចុះបញ្ជីឡើងវិញជាមួយគណៈឆ្មបកម្ពុជារៀងរាល់៣ឆ្នាំម្តងនិងឆ្មបបរទេសរៀងរាល់១ឆ្នាំម្តង។ ការធ្វើដូចនេះមានសារៈសំខាន់សម្រាប់សុវត្ថិភាពសាធារណៈជន ព្រោះវាអាចធានាបានថា ឆ្មបដែលបានចុះបញ្ជីទាំងអស់បានបំពេញតាមស្តង់ដានៃការចុះបញ្ជីឡើងវិញនិងលក្ខខណ្ឌតម្រូវក្នុងការអភិវឌ្ឍន៍វិជ្ជាជីវៈបន្តនោះជាមធ្យោបាយដើម្បីឱ្យឆ្មបរក្សា ពង្រឹង ពង្រីកចំណេះដឹង ជំនាញ ព្រមទាំងសមត្ថភាព និងអភិវឌ្ឍគុណភាពវិជ្ជាជីវៈផ្ទាល់ខ្លួនពេញមួយជីវិតនៃការប្រកបវិជ្ជាជីវៈ។

ការអភិវឌ្ឍន៍វិជ្ជាជីវៈបន្តត្រូវចាប់ផ្តើមភ្លាមក្រោយពីបានទទួលការអប់រំ/ការបណ្តុះបណ្តាលមូលដ្ឋានដែលរួមមានការពិនិត្យមើលឡើងវិញនូវការអនុវត្តន៍ ការកំណត់នូវតម្រូវការនៃការសិក្សា ការរៀបចំផែនការ និងការចូលរួមក្នុងវគ្គបណ្តុះបណ្តាលបន្ត កត់ត្រាពីសារៈសំខាន់និងចំនួននៃវគ្គបណ្តុះបណ្តាលបន្តដែលខ្លួនបានចូលរួម។

២. ការអនុញ្ញាតិឬការផ្តល់សិទ្ធិ

គណៈឆ្មបកម្ពុជាបានអនុម័តស្តង់ដានេះនៅថ្ងៃទី ខែ ឆ្នាំ ដោយអនុលោមទៅតាមព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈឆ្មបកម្ពុជាលេខនស/រកត/០៩០៦/៣៨៩ និងអនុក្រឹត្យស្តីពីក្រមសីលធម៌ឆ្មបត្រង់មាត្រាទី៥ចំនុចទី៦។

៣. សេចក្តីសង្ខេប

ស្តង់ដានេះកំណត់ពីលក្ខខ័ណ្ឌតម្រូវអប្បរមាសម្រាប់ការចុះបញ្ជីឡើងវិញនិងការអភិវឌ្ឍន៍វិជ្ជាជីវៈបន្តដែលទាក់ទងផ្ទាល់ទៅនឹងការអនុវត្តន៍ការងាររបស់ឆ្មប។ គណៈឆ្មបកម្ពុជារក្សាសិទ្ធិរបស់ខ្លួនក្នុងការលើកលែងសម្រាប់ករណីផ្សេងៗគ្នា។

៤.វិសាលភាពនៃការអនុវត្ត

ស្តង់ដានេះអនុវត្តលើសមាជិករបស់គណៈឆ្មបកម្ពុជាដែលកំពុងអនុវត្តការងារឆ្មបទាំងអស់និងបានចុះបញ្ជីជាមួយគណៈឆ្មបកម្ពុជារួមមាន: ឆ្មបអនុវត្តវិជ្ជាជីវៈឆ្មប គ្រូបង្រៀនឆ្មប អ្នកគ្រប់គ្រងឆ្មប អ្នកស្រាវជ្រាវការងារឆ្មបដែលការងារទាំងនោះមានឥទ្ធិពលលើការអនុវត្តន៍ការងារឆ្មប។

ស្តង់ដានេះមិនអនុវត្តទៅលើឆ្មបដែលចុះបញ្ជីក្នុងប្រភេទឆ្មបមិនមានជំនាញគ្លីនិក។ ឆ្មបមិនមានជំនាញគ្លីនិកត្រូវចុះបញ្ជីឡើងវិញប៉ុន្តែមិនតម្រូវឲ្យបំពេញតាមស្តង់ដារនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តនោះទេ។

៥. លក្ខខណ្ឌតម្រូវនិងស្តង់ដានៃការចុះបញ្ជីឡើងវិញ

ក. ស្តង់ដានៃការអនុវត្តវិជ្ជាជីវៈឆ្មប

ក.១ ឆ្មបជនជាតិខ្មែរ

ឆ្មបជនជាតិខ្មែរដែលអនុវត្តន៍វិជ្ជាជីវៈឆ្មបត្រូវប្រើប្រាស់នូវគុណវុឌ្ឍិរបស់ខ្លួនយ៉ាងតិចបំផុត ៥០០ម៉ោង ក្នុង១ឆ្នាំ ឬ ១,៥០០ម៉ោង ក្នុងរយៈពេល៣ឆ្នាំ មុននឹងកាលបរិច្ឆេទកំណត់នៃការចុះបញ្ជីឡើងវិញ។

ក.២ ឆ្មបបរទេស

ឆ្មបបរទេសដែលអនុវត្តន៍វិជ្ជាជីវៈឆ្មបត្រូវប្រើប្រាស់នូវគុណវុឌ្ឍិរបស់ខ្លួនយ៉ាងតិចបំផុត៥០០ ម៉ោង ក្នុងរយៈពេល១ឆ្នាំ មុននឹងកាលបរិច្ឆេទកំណត់នៃការចុះបញ្ជីឡើងវិញ និងបំពេញតាមលក្ខខណ្ឌតម្រូវផ្សេងទៀតដែលកំណត់ក្នុងសេចក្តីសម្រេចស្តីពីការកំណត់ប្រភេទ និងលក្ខខណ្ឌនៃការចុះបញ្ជីឆ្មប។

គោលបំណងនៃស្តង់ដានេះគឺដើម្បីការពារសាធារណជនដោយធានាថាឆ្មបដែលចុះបញ្ជីឡើងវិញបានបំពេញតាមលក្ខខណ្ឌតម្រូវនៃការអនុវត្តវិជ្ជាជីវៈឆ្មបដើម្បីធានាថាសេវាដែលខ្លួនបានផ្តល់មានសុវត្ថិភាព។

ប្រសិនបើឆ្មបមិនបានបំពេញតាមលក្ខខណ្ឌខាងលើនោះ

ឆ្មបជនជាតិខ្មែរនិងបរទេសត្រូវ:

- ចូលរួមវគ្គបណ្តុះបណ្តាលដែលអនុម័តដោយក្រសួងសុខាភិបាល ដើម្បីឲ្យឆ្មបអាចបំពេញតាមស្តង់ដានៃការអនុវត្តវិជ្ជាជីវៈឆ្មប ឬ
- អនុវត្តន៍ការងារស្ថិតក្រោមការអភិបាលដោយឆ្មបដែលបានចុះបញ្ជីក្នុងប្រភេទឆ្មបទូទៅក្នុងរយៈពេល៣ខែនិងទទួលបានលិខិតបញ្ជាក់សមត្ថភាពដើម្បីធានាថាមានចំណេះដឹង និងជំនាញថ្មីៗ និងអាចឆ្លើយតបទៅនឹងសមត្ថភាពស្នូល និងក្រមសីលធម៌ឆ្មបដែលកំណត់ដោយគណៈឆ្មបកម្ពុជា។

ខ. ស្តង់ដានៃការអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត

ឆ្មបជនជាតិខ្មែរ និងបរទេសដែលបានចុះបញ្ជីទាំងអស់ត្រូវគោរពតាមលក្ខខណ្ឌតម្រូវនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត។ ទោះបីជាឆ្មបមិនមានជំនាញគ្លីនីកត្រូវបានលើកលែងប៉ុន្តែគណៈឆ្មបកម្ពុជាលើកទឹកចិត្តឆ្មបឲ្យទទួលការបណ្តុះបណ្តាលបន្តដែលទាក់ទងនឹងការងាររបស់ខ្លួន។ ការសិក្សាមួយម៉ោងស្មើនឹងមួយម៉ោងនៃការអភិវឌ្ឍន៍វិជ្ជាជីវៈបន្ត និងរាល់ឯកសារដែលជាភស្តុតាងទាំងអស់ត្រូវធ្វើការផ្ទៀងផ្ទាត់។

ឆ្មបជនជាតិខ្មែរ និងបរទេសត្រូវ៖

- ទទួលខុសត្រូវក្នុងការកត់ត្រាចំនួនម៉ោងដែលខ្លួនបានសិក្សា។
- រក្សាទុកនូវឯកសារដែលជាភស្តុតាងបង្ហាញពីការអភិវឌ្ឍវិជ្ជាជីវៈបន្តរបស់ខ្លួនសម្រាប់រយៈពេលយ៉ាងតិចបំផុត៤០ម៉ោងក្នុងមួយឆ្នាំ ឬ១២០ម៉ោងក្នុងបីឆ្នាំ។

- បំពេញកំណត់ត្រានៃការអភិវឌ្ឍន៍វិជ្ជាជីវៈបន្តរបស់ខ្លួនដោយរួមបញ្ចូលនូវៈកាលបរិច្ឆេទនៃការសិក្សា ព័ត៌មានឆ្លុះបញ្ចាំងពីខ្លឹមសារនៃការសិក្សារបស់ខ្លួន លទ្ធផល និងចំនួនម៉ោងដែលបានសិក្សា។

៦. តួនាទីរបស់គណៈឆ្មបកម្ពុជា

គណៈឆ្មបកម្ពុជានឹងតាមដានមើលលើសមត្ថភាពនៃការអនុវត្តការងាររបស់ឆ្មបនិងធ្វើសវនកម្មលើឆ្មបមួយចំនួនស្តីពីការបំពេញការអភិវឌ្ឍន៍វិជ្ជាជីវៈបន្តជាទៀងទាត់។

៧. ការត្រួតពិនិត្យឡើងវិញ

ស្តង់ដានេះនឹងមានសុពលភាពចាប់ពីថ្ងៃទី ខែ ឆ្នាំ និងត្រូវពិនិត្យឡើងវិញរៀងរាល់ ៣ឆ្នាំម្តង។

៨. ឯកសារយោង

- ព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈឆ្មបកម្ពុជាលេខនស/រកត/០៩០៦/៣៨៩
- អនុក្រឹត្យស្តីពីក្រមសីលធម៌ឆ្មបលេខ ២៥ អនក្រ.បកប្រការ ៥ (៦)
- គោលការណ៍ណែនាំស្តីពីស្តង់ដានៃការចុះបញ្ជីឡើងវិញ និងលក្ខខណ្ឌតម្រូវក្នុងការអភិវឌ្ឍន៍វិជ្ជាជីវៈបន្តសម្រាប់ឆ្មប
- Singapore Nursing Board www.healthprofessionals.gov.sg
- Thailand Nursing and Midwifery Council: Centre for Continuing Education www.ccne.or.th/download/sec_license.htlm
- Midwifery Council of New Zealand re-certification programme www.midwiferycouncil.health.nz/recertification-elective-education/
- Nursing and Midwifery Board of Australia `Continuing Professional Development Registration Standard www.nursingmidwiferyboard.gov.au